

# ការធ្វើតាមព្រះយេស៊ូវនៅ ប្រទេស គីរីបាទី



## ជួប ស្កុត !



### អំពី ស្កុត

អាយុ ៖ ៨ឆ្នាំ

មកពី ៖ តារ៉ាវ៉ា ប្រទេសគីរីបាទី

ភាសា ៖ ភាសា គីរីបាទី និងភាសាអង់គ្លេស

គោលដៅ និង ក្ដីសុបិន ៖ ចង់ក្លាយជាវេជ្ជបណ្ឌិត

គ្រួសារ ៖ ម៉ាក់ និងស្កុត



## របៀបដែលស្កុតធ្វើតាមព្រះយេស៊ូវ

ស្កុត គឺជាក្មេងចេះស្ដាប់បង្គាប់ និងចិត្តល្អ ។ គាត់ចូលចិត្តធ្វើជាគំរូល្អ ជាពិសេសដល់បងប្អូនជីដូនមួយតូចៗរបស់គាត់ ។ គាត់គឺជាមិត្តដ៏ល្អរបស់បងប្អូនជីដូនមួយរបស់គាត់ ដែលគាត់តែងតែហៅជីដូនមួយគាត់ថាជាប្អូនរបស់គាត់ ។ ស្កុត អធិស្ឋានរៀងរាល់ពេលយប់ និងពេលព្រឹក ។ គាត់តែងតែចង់ទៅសកម្មភាពនៅសាសនាចក្រ ហើយគាត់ចូលចិត្តរាត្រីជួបជុំគ្រួសារ ។ គាត់ចូលចិត្តជួយអ្នកដទៃផងដែរ ។ គាត់ចង់ជួយពួកគេពីព្រោះគាត់មានអារម្មណ៍ល្អនៅពេលគាត់ជួយគេ ។ គាត់និយាយថា « ការជួយអ្នកដទៃធ្វើឲ្យខ្ញុំសប្បាយចិត្ត » ។●



### អ្នកក៏អាចធ្វើតាមព្រះយេស៊ូវបានដែរ !

មានវិធីជាច្រើនដើម្បីធ្វើតាមព្រះយេស៊ូវ ។ តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីធ្វើតាមទ្រង់បាន ? សូមសរសេរប្រាប់យើង !

### ចំណូលចិត្តរបស់ស្កុត

ដំណើររឿងក្នុងព្រះគម្ពីរ ៖
នៅពេលព្រះយេស៊ូវគ្រីស្ទបានប្រសូតមក



ទីកន្លែង ៖
ផ្ទះជីដូនជីតារបស់គាត់

បន្លែ និងផ្លែឈើ ៖
ផ្លែប៉ោម ផ្កាខាត់ណាខៀវ





មុខវិជ្ជានៅសាលា ៖
អង់គ្លេស

ពណ៌ ៖
ខៀវ

